Rattanak

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

លេខ ៨៨១៧ កសក

# ដីការអម

**គោរពជូនៈ -ឯកឧត្តម លោកជំទាវថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**
**-ឯកឧត្តម លោក លោកស្រី ប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួង**

| ល.រ | រាយមុខលិខិត | ចំនួន | សេចក្តីផ្សេងៗ |
|---|---|---|---|
| ១ | -របាយការណ៍ស្តីពីសភាពការណ៍កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ **ប្រចាំនព្វមាស ឆ្នាំ២០២០** និងទិសដៅអនុវត្តបន្ត.............. | ០១ច្បាប់ | "ដើម្បីជូនជ្រាប" --------- |

ថ្ងៃ [illegible] ខែ អស្សុជ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ ១០ ឆ្នាំ២០២០

**ត.ប.រដ្ឋមន្ត្រី**
**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**
**អគ្គលេខាធិការ**

**ស្រី វុឌ្ឍី**

អាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទលេខៈ (០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខៈ (៨៥៥) ២៣ ២១៧ ៣២០
Nº 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia
Phone: (023) 726 128 / 726 129, Fax: (855) 23-217 320

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# របាយការណ៍
# ស្តីពី
# សភាពការណ៍កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រចាំ៧ខែ ឆ្នាំ២០២០ និងទិសដៅអនុវត្តបន្ត

## I- សភាពការណ៍រួម

នៅក្នុង៧ខែ ឆ្នាំ២០២០នេះ ការងារបង្កបង្កើនផលស្រូវរដូវវស្សាធ្វើការដាំដុះបានចំនួន ២ ៧១៤ ២១៦ហ.ត ស្មើនឹង១០៤,៨៧% នៃផែនការចំនួន ២ ៥៨៨ ១៣០ហ.ត។ រីឯការចូលរួមទប់ស្កាត់បទល្មើសផ្សេងៗទៀតជាពិសេស បទល្មើសព្រៃឈើ បទល្មើសជលផលក្រោមកិច្ចសហការជាមួយគណៈកម្មការអន្តរក្រសួង ព្រមទាំងបទល្មើសចលនាសត្វដោយខុសច្បាប់ត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាព។ ចំណែកឯការចុះធ្វើអធិការកិច្ចជី-ថ្នាំកសិកម្ម ការជំរុញការងារផ្សព្វផ្សាយកសិកម្មតាមគ្រប់រូបភាពបានប្រព្រឹត្តទៅក្រោមកិច្ចសហប្រតិបត្តិការយ៉ាងល្អប្រសើរជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ និងសហគមន៍កសិកម្មទៅតាមភារកិច្ចក្នុងស្មារតីទទួលខុសត្រូវ។ ទន្ទឹមនឹងនេះ ព្រឹត្តិការណ៍សំខាន់ៗក្នុង៧ខែ ឆ្នាំ២០២០នេះ គឺបានរៀបចំកិច្ចប្រជុំសំខាន់ៗ រួមទាំងការបន្តរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានាផងដែរ។ ចំពោះលទ្ធផល និងសកម្មភាពការងារសំខាន់ៗតាមផ្នែកផ្សេងៗឆ្លើយតបទៅនឹងការអនុវត្តផែនការប្រចាំឆ្នាំ២០២០ រួមទាំងការចូលរួមអនុវត្តកំណែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាលដែលសម្រេចបានក្នុង៧ខែ ឆ្នាំ២០២០នេះ មានដូចតទៅ៖

## II- លទ្ធផលសម្រេចបានតាមបណ្តាផ្នែក

### ១ លទ្ធផលផ្នែកដាំដុះ

#### ១.១ ផលិតកម្មដំណាំស្រូវរដូវវស្សា

ល្បឿនការងារបង្កបង្កើនផលដំណាំស្រូវរដូវវស្សាគិតត្រឹមថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២០ មានលម្អិតដូចខាងក្រោម៖

- ផ្ទៃដីភ្ជួររាស់សម្រេចបានចំនួន ២ ៧៦៧ ២៧១ហ.ត ក្នុងនោះភ្ជួររាស់ដោយគោ-ក្របីមានចំនួន ២៥ ៩៦៨ហ.ត និងដោយគ្រឿងយន្តមានចំនួន ២ ៧៤១ ៣០៣ហ.ត លើសឆ្នាំមុនចំនួន ២៦ ០៩៦ហ.ត
- ផ្ទៃដីសាបសម្រេចបានចំនួន ១៥ ៧៨២ហ.ត តិចជាងឆ្នាំមុនចំនួន ៦ ៩៨៤ហ.ត
- ផ្ទៃដីស្ទូង និងព្រោះសម្រេចបានចំនួន ២ ៧១៤ ២១៦ហ.ត ស្មើនឹង១០៤,៨៧% នៃផែនការចំនួន ២ ៥៨៨ ១៣០ហ.ត លើសឆ្នាំមុនចំនួន ៧០ ២១៧ហ.ត។

#### ១.២ ការប្រមូលផលស្រូវស្រាលដើមរដូវវស្សា

ការប្រមូលផលស្រូវស្រាលសម្រេចបានចំនួន ៤៣៦ ២៨៧ហ.ត ដោយទទួលបរិមាណផលសរុបចំនួន ១ ៦៦២ ០៦១តោន លើសឆ្នាំមុនចំនួន ២៤៦ ៦១៨តោន និងទទួលបានទិន្នផលគិតជាមធ្យម ៣,៨១០តោន/ហ.ត។

#### ១.៣ ដំណាំសាកវប្បកម្ម និងដំណាំឧស្សាហកម្មរដូវវស្សា

-ដំណាំសាកវប្បកម្មអនុវត្តបានសរុបចំនួន ៦៤ ៦៤៤ហ.ត ស្មើនឹង១៣០,៧៩% នៃផែនការចំនួន ៤៩ ៤២៤ហ.ត លើសឆ្នាំមុនចំនួន ១៣ ២១២ហ.ត

-ដំណាំឧស្សាហកម្មអនុវត្តបានសរុបចំនួន ៧៩៤ ២៩៨ហ.ត ស្មើនឹង៩០,៨២% នៃផែនការចំនួន ៨៧៤ ៥៩៥ហ.ត តិចជាងឆ្នាំមុនចំនួន ៧១ ៦១៦ហ.ត។

### ១.៤ ការនាំចេញផលិតផលកសិកម្ម

#### ១.៤.១ ការនាំចេញអង្ករ

បរិមាណនាំចេញអង្ករបានចំនួន ៤៨៨ ៧៧៥តោន មានការកើនឡើងចំនួន ៩០ ១៨៩តោន (+២២,៦៣%) ច្រើនជាងបរិមាណនាំចេញក្នុងរយៈពេល៩ខែឆ្នាំ២០១៩ មានចំនួន ៣៩៨ ៥៨៦តោន។ ការនាំចេញទៅកាន់ទិសដៅចំនួន ៦០ប្រទេស ក្នុងនោះប្រទេសចិនលំដាប់ទី១ចំនួន ១៧១ ៨៩៦តោន ប្រទេសបារាំងលំដាប់ទី២ចំនួន ៦២ ០១២តោន ប្រទេសហូឡង់លំដាប់ទី៣ចំនួន ៣៩ ២៧៣តោន ប្រទេសម៉ាឡេស៊ីលំដាប់ទី៤ចំនួន ២៧ ៧៧៨តោន ប្រទេសអូស្ត្រាលីលំដាប់ទី៥ចំនួន ២៣ ៥៦៩តោន ប្រទេសណេដឺឡង់លំដាប់ទី៦ចំនួន ២០ ៤២០តោន ប្រទេសវៀតណាមលំដាប់ទី៧ចំនួន ១២ ៨៣៦តោន ប្រទេសអង់គ្លេសលំដាប់ទី៨ចំនួន ១២ ៣០១តោន ប្រទេសប្រ៊ុយណេលំដាប់ទី៩ចំនួន ១២ ២០១តោន និងប្រទេសអេស្ប៉ាញលំដាប់ទី១០ចំនួន ១០ ៧០៩តោន ហើយបច្ចុប្បន្នក្រុមហ៊ុនបាននាំចេញអង្ករមានចំនួន ៧១ក្រុមហ៊ុន។

#### ១.៤.២ ការនាំចេញផ្លែឈើ

បរិមាណនាំចេញផ្លែចេកស្រស់បានចំនួន ២១០ ៨០៤,២៦តោន ទៅកាន់ប្រទេសចិន វៀតណាម សិង្ហបុរី និងប្រទេសជប៉ុន។ ផ្លែស្វាយស្រស់ ៥០ ៩២០,៥៦តោន ទៅកាន់ប្រទេសកូរ៉េ បារាំង ហុងកុង រុស្ស៊ី សិង្ហបុរី ថៃ និងប្រទេសវៀតណាម។ គ្រាប់ពោត ១៩៣ ៦៦០,២៤តោន ទៅកាន់ប្រទេសថៃ កូរ៉េ និងតៃវ៉ាន់។

## ២ ផ្នែកផលិតកម្មកៅស៊ូ

#### ២.១ ផ្ទៃដីកៅស៊ូ

- ផ្ទៃដីកៅស៊ូសរុបចំនួន ៤០៣ ១៩៥ហ.ត ក្នុងនោះ ផ្ទៃដីចៀរជ័រចំនួន ២៩០ ៦០៩ហ.ត ស្មើនឹង៧២% និងផ្ទៃដីថែទាំចំនួន ១១២ ៥៨៦ហ.ត ស្មើនឹង៣៨%។

#### ២.២ ផលិតកម្មកៅស៊ូ

- ផលិតផលជ័រកៅស៊ូសម្រេចបានចំនួន ១៨២ ៤៩៧តោន កើនឡើងចំនួន ៣១ ០៤៥តោន ស្មើនឹង២០% ធៀបនព្វមាស ឆ្នាំ២០១៩។

#### ២.៣ ការនាំចេញកៅស៊ូ

- បរិមាណបញ្ចេញលក់សម្រេចបានចំនួន ១៧៩ ៦២១តោន កើនឡើងចំនួន ៣០ ២៦៧តោន ស្មើនឹង២០% ធៀបនព្វមាស ឆ្នាំ២០១៩។

#### ២.៤ តម្លៃកៅស៊ូ

- តម្លៃលក់មធ្យមក្នុងខែកញ្ញា គឺ១ ២៦៦ដុល្លារ/តោន កើនឡើងចំនួន ២៦ដុល្លារ/តោន ស្មើនឹង២,០៩% ធៀបខែមុន និងថយចុះ ៦៤ដុល្លារ/តោន ស្មើនឹង៥% ធៀបខែកញ្ញា ឆ្នាំ២០១៩
- តម្លៃលក់មធ្យមក្នុងនព្វមាស គឺ១ ២៨៨ដុល្លារ/តោន ថយចុះចំនួន ៥១ដុល្លារ/តោន ស្មើនឹង៤% ធៀបនព្វមាស ឆ្នាំ២០១៩
- តម្លៃប្រមូលទិញជ័រកៅស៊ូគ្រួសារចម្ការក្នុងនព្វមាស គឺទឹកជ័រ (DRC 100%) មានការប្រែប្រួលពី ៤ ១០០៛/គ.ក្រ ដល់ ៤ ៣៧៥៛/គ.ក្រ និងជ័រកក (DRC50%) មានការប្រែប្រួលពី ១ ៩០០៛/គ.ក្រ ដល់ ២ ៣៥០៛/គ.ក្រ។

## ៣ ផ្នែកព្រៃឈើ

### ៣.១ ការងារព្រៃឈើ

- បានចេញសេចក្តីប្រកាសស្តីពីការបង្កើត និងការគ្រប់គ្រងតំបន់ព្រៃសហគមន៍ចំនួន ៣កន្លែង មានផ្ទៃដីសរុបទំហំ ១ ២៤៩,៥៨ហ.ត ស្ថិតក្នុងខេត្តកំពង់ធំ និងខេត្តក្រចេះចំនួន ២កន្លែង
- បានយល់ព្រមគោលការណ៍លើផែនការគ្រប់គ្រងព្រៃសហគមន៍ចំនួន ៩កន្លែងមានផ្ទៃដីសរុបទំហំ ៦ ៩២០,១ហ.ត ក្នុងនោះខេត្តស្ទឹងត្រែងចំនួន ៤កន្លែង កំពតចំនួន ២កន្លែង កោះកុងចំនួន ១កន្លែង និងខេត្តព្រះវិហារចំនួន ២កន្លែង
- បានផ្តល់ប័ណ្ណសម្គាល់សិទ្ធិប្រើប្រាស់រណារយន្ត និងយានយន្តជូនក្រុមហ៊ុនចំនួន ១០ក្រុមហ៊ុន និងអ្នកស្នើសុំចំនួន ៤នាក់ មានរណារយន្តសរុបចំនួន ១៤៩គ្រឿង និងយានយន្តចំនួន ១៣៣គ្រឿង

- បានផ្តល់លិខិតបើកផ្លូវដឹកជញ្ជូនផលអនុផលព្រៃឈើជូនក្រុមហ៊ុនចំនួន ៧ក្រុមហ៊ុន និងអ្នកស្នើសុំចំនួន ១២ នាក់។

### ៣.២ ការងារអភិរក្សសត្វព្រៃ

- បានចុះសិក្សាស្រាវជ្រាវ និងធ្វើការតាមដានវត្តមានសត្វព្រៃចំនួន ៤លើក នៅក្នុងតំបន់ព្រៃបម្រុងទុកអចិន្ត្រៃយ៍ ស្ថិតក្នុងខេត្តរតនគីរី ក្រចេះ និងខេត្តព្រះវិហារ ដោយកត់ត្រាបាននូវប្រភេទសត្វព្រៃមានដូចជាថនិកសត្វចំនួន ៥១ប្រភេទ បក្សីចំនួន ៦៨ប្រភេទ និងឧរង្គសត្វចំនួន ៣៦ប្រភេទ

- បានចេញលិខិតអនុញ្ញាតថែរក្សាសត្វព្រៃជាលក្ខណៈគ្រួសារចំនួន ១០២ច្បាប់ ក្នុងនោះ ៩៤ច្បាប់សម្រាប់ការថែរក្សាសត្វត្រចៀកកាំ និង៨ច្បាប់សម្រាប់ការថែរក្សាសត្វព្រៃប្រភេទផ្សេងទៀតដែលមាន ទីតាំងស្ថិតនៅរាជធានីភ្នំពេញ ខេត្តកោះកុង កំពត បាត់ដំបង ពោធិ៍សាត់ រតនគីរី កំពង់ចាម សៀមរាប បន្ទាយមានជ័យ និងខេត្តកណ្តាល

- បានចេញលិខិតអនុញ្ញាតនាំចូល នាំចេញសត្វព្រៃមានដោយបង្កចំនួន ៤ច្បាប់ មានដុកដឿចំនួន ៤ ០០០ក្បាល ជូនមជ្ឈមណ្ឌលសួនមេអំបៅបន្ទាយស្រីសម្រាប់នាំចេញទៅកាន់ប្រទេសអង់គ្លេសចំនួន ១ ០០០ក្បាល និងប្រទេសហូឡង់ ចំនួន ៣ ០០០ក្បាល។

### ៣.៣ កសិដ្ឋានចិញ្ចឹម បង្កាត់ពូជសត្វក្តាម និងការសង្គ្រោះសត្វព្រៃ

- ក្រុមហ៊ុនចំនួន ៧មានកសិដ្ឋានស្រាវជ្រាវ ចិញ្ចឹម និងបង្កាត់ពូជសត្វស្វាក្តាមយកកូននាំចេញចំនួន ៨កន្លែង ស្ថិតនៅរាជធានីភ្នំពេញ ខេត្តកំពង់ធំ សៀមរាប កំពង់ចាម កំពង់ស្ពឺ ពោធិ៍សាត់ និងខេត្តកំពង់ឆ្នាំងមានស្វាក្តាមសរុបចំនួន ៦៨ ៥១១ក្បាល ក្នុងនោះកូនកើតរយៈពេល៩ខែ មានចំនួន ៣០ ៧៩៨ក្បាល

- នៅឧទ្យានសួនសត្វ និងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅមានសត្វព្រៃសរុបចំនួន ១ ៦២២ក្បាល (បក្សីចំនួន ៥៦ប្រភេទ ថនិកសត្វចំនួន ៤៦ប្រភេទ និងល្មូនចំនួន ១៦ប្រភេទ) សង្គ្រោះសត្វថ្មីចំនួន ១ ២៩៨ក្បាល ព្យាបាលសត្វព្រៃរបួសឈឺចំនួន ២៧៩ក្បាល ស្តារលទ្ធភាពជីវសាស្ត្រសត្វព្រៃ និងដោះលែងទៅព្រៃធម្មជាតិវិញនូវសត្វព្រៃគ្រប់ប្រភេទ ចំនួន ១ ០៥១ក្បាល

- គម្រោងអភិរក្សក្រពើកម្ពុជាក្នុងកិច្ចសហការជាមួយអង្គការ FFI បានល្បាតនៅតំបន់ដែនជម្រកក្រពើសំខាន់ៗ ចំនួន ៥ គឺ អារ៉ែង ឆាយរាប តំបន់ស្តារក្រពើស្ទឹងដាច់ ស្ទឹងខៀវ (ខេត្តកោះកុង) និងអូរសោម (ខេត្តពោធិ៍សាត់)

- បានជួសជុលផ្លូវក្រាលក្រួសក្រហមសរុបប្រវែង ៨០ ៩២០ម៉ែត្រការ៉េ និងកាប់ឆ្ការអនាម័យព្រៃទំហំ ២៥,៥៦ហ.ត នៅក្នុងតំបន់សួនសត្វ។

### ៣.៤ ការងារដាំដើមឈើ

- បាននិងកំពុងថែទាំប្រឡាយប្រវែង ១៨ ០០០ម៉ែត្រ ក្នុងនោះប្រឡាយជីកឆ្នាំ២០១៨ ប្រវែង ១០ ០០០ម៉ែត្រ និងឆ្នាំ២០១៩ មានប្រវែង ៨ ០០០ម៉ែត្រ ស្ថិតនៅក្នុងខេត្តកំពង់ធំ និងខេត្តព្រះសីហនុ

- បាននិងកំពុងថែទាំចម្ការឈើសរុប ៩៣២ហ.ត ក្នុងនោះចម្ការពូជឈើ ៨៩ហ.ត ឡូតិ៍បង្ហាញកសិ-រុក្ខកម្ម៤៩ហ.ត ចម្ការឈើដាំទំហំ ៧៥៤ហ.ត និងចម្ការរុក្ខទិវា ៩ កក្កដា ទំហំ៤០ហ.ត ស្ថិតក្នុងខេត្តកំពត កណ្តាល សៀមរាប ព្រះសីហនុ ស្វាយរៀង កំពង់ធំ និងខេត្តក្រចេះ

- បានដាំឈើជាចម្ការថ្មីទំហំ ១៥០ហ.ត ក្នុងនោះនៅស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើអន្លង់ថ្មស្ថិតក្នុងខេត្តកំពង់ធំទំហំ ១០០ហ.ត និងស្ថានីយដាំឈើម្សៅក្រជាស ហ៊ុន សែន មានក ទំហំ ៥០ហ.ត និងដាំកូនឈើសរុបចំនួន ២៤៩ ៩០០ដើម

- បានបណ្តុះកូនឈើចំនួន ៥៣១ ៧៣៨ដើម ក្នុងនោះថ្នាលបណ្តុះកូនឈើតាមបណ្តាខណ្ឌរដ្ឋបាលព្រៃឈើនៅទូទាំងប្រទេសចំនួន ៣៦៣ ០៣៨ដើម នាយកដ្ឋានអភិវឌ្ឍន៍ចម្ការព្រៃដាំ និងព្រៃឯកជនបានចំនួន ១៦៨ ៧០០ដើម និងចែកចាយកូនឈើចំនួន ៤០៤ ១៨១ដើម (ខណ្ឌរដ្ឋបាលព្រៃឈើនៅទូទាំងប្រទេសចំនួន ៣១៩ ៥៣១ដើម និងនាយកដ្ឋានអភិវឌ្ឍន៍ចម្ការព្រៃដាំ និងព្រៃឯកជនបានចំនួន ៨៤ ៦៥០ដើម)។

### ៣.៥ ការងារនីតិកម្មនិងវិវាទ

- សំណុំរឿងបទល្មើសព្រៃឈើ សត្វព្រៃ និងកាប់រានដីព្រៃសរុបចំនួន ១ ១៥២ករណី ដោយពិន័យអន្តរការណ៍ចំនួន ៤៦៤ករណី និងបញ្ជូនទៅតុលាការចំនួន ៦៨៨ករណី

- ចំពោះវត្ថុតាងនៃបទល្មើសព្រៃឈើដែលបានចាប់ឃាត់ និងដកហូតរួមមានឈើមូល-ជ្រុងសរុបចំនួន ១៣៩ម៣ ឈើអារចំនួន ២ ៣៦៧ម៣ ផ្ទៃដីព្រៃឈើដែលបានកាប់រានទំហំ ២ ៣៩៩ហ.ត វត្ថុតាងសត្វព្រៃដែលបានចាប់ឃាត់មានចំនួន ៣ ០៩៩ក្បាល និង១ ០១៧គ.ក្រ និងអនុផលព្រៃឈើ ព្រមទាំងសម្ភារផ្សេងៗមួយចំនួនទៀត។

### ៣.៦ ការងារឧស្សាហកម្មនិងពាណិជ្ជកម្ម

- បានបង្កើតរោងសន្និធិលក់ចែកចាយផល អនុផលព្រៃឈើប្រភេទធំចំនួន ១១ស្ថិតនៅក្នុងរាជធានីភ្នំពេញ ខេត្តតាកែវ ស្វាយរៀង រតនគីរី ព្រៃវែង កំពង់ធំ កណ្តាល កំពង់ស្ពឺ កំពង់ចាម ត្បូងឃ្មុំ និងខេត្តសៀមរាបស្មើនឹង១៥កន្លែង

- បានបង្កើតរោងម៉ាស៊ីនអារកែច្នៃឈើ និងឡផ្សែងចំនួន ១០កន្លែង
- បានពន្យារសុពលភាពរោងម៉ាស៊ីនអារកែច្នៃឈើចំនួន ១០កន្លែង
- ក្រុមហ៊ុនចំនួន ៨បាននាំចេញផលិតផលរានទេវតា ឈើកែច្នៃ ជ័រទឹក និងកម្ទេចឈើទៅក្រៅប្រទេសចំនួន ១ ៨៥២ម៣ ជ័រទឹកចំនួន ២៦៩តោន និងកម្ទេចឈើចំនួន ៤ ០០០តោន និងក្រុមហ៊ុនចំនួន ៥បាននាំចូលឈើកែច្នៃមានបរិមាណចំនួន ១ ៥៥៧ម៣
- បានផ្តល់ទិដ្ឋាការអាជ្ញាប័ណ្ណនាំចេញជូនក្រុមហ៊ុនចំនួន ១២មានបរិមាណឈើកែច្នៃចំនួន ៤ ២៦២ម៣ ឈើអាកាស្យាកាត់ជាកង់ៗចំនួន ១ ៥០០ស្ទែរ កម្ទេចឈើចំនួន ៤ ០០០តោន ធ្យូងអាកាស្យាចំនួន ៤១តោន និងឫស្សីកែច្នៃចំនួន ៤២តោន និងជ័ទឹកចំនួន ២៤៨តោន
- បានផ្តល់ទិដ្ឋការអាជ្ញាប័ណ្ណនាំចូលជូនក្រុមហ៊ុនចំនួន ៥មានបរិមាណឈើកែច្នៃ (MDF, Wood Panell Dark Red Meranti, Doussie, Chanfuta) ចំនួន ២ ២៤៥ម៣។

### ៣.៧ ការងារចំណូលព្រៃឈើ

- បានចំណូលពីថ្លៃសួយសារផលអនុផលព្រៃឈើចំនួន ១២ ៨២៥ ០១៥ ៨៩៨រៀល និង១ ២៩៧ ៤៩១,០៣ ដុល្លារ។

## ៤ ផ្នែកផលិតកម្មសត្វ និងសុខភាពសត្វ

**៤.១ ការងារផលិតកម្មសត្វ៖** បាននិងកំពុងពង្រឹងការងារផលិតកម្មសត្វតាមរយៈការបណ្តុះបណ្តាលគ្រូបង្គោលលើជំនាញបច្ចេកទេសចិញ្ចឹមសត្វ ចុះតាមដានស្ថានភាពចិញ្ចឹមសត្វ ណែនាំបច្ចេកទេសចិញ្ចឹមដល់កសិករចិញ្ចឹមសត្វជាលក្ខណៈគ្រួសារនៅតាមបណ្តាខេត្ត និងបន្តរៀបចំកែសម្រួលឯកសារបច្ចេកទេសចិញ្ចឹមគោ ជ្រូក មាន់ជាលក្ខណៈគ្រួសារ ព្រមទាំងតាមដានស្ថានភាពតម្លៃសត្វពីបណ្តារាជធានី-ខេត្តរៀងរាល់សប្តាហ៍។ ក្រៅពីនេះ អង្គភាពជំនាញកំពុងបន្តអនុវត្ត៖ (ក) ការងារកែលម្អពូជតាមរយៈការចុះអប់រំផ្សព្វផ្សាយពីការជ្រើសរើសពូជសត្វប្រកបដោយគុណភាព (ខ) ការលើកកម្ពស់ការយល់ដឹងខ្ពស់លើការប្រើប្រាស់ចំណីសត្វ និងចំណីផ្សំស្រេចប្រកបដោយគុណភាព និងសុវត្ថិភាព ព្រមទាំងបន្តផ្សព្វផ្សាយអំពីអត្ថប្រយោជន៍នៃការដាំដំណាំចំណីសត្វ ការធ្វើស្ងួនដំណាំចំណីសត្វ ការផ្តល់ពូជស្មៅដល់កសិករ និងភ្នាក់ងារសុខភាពសត្វភូមិ និងចុះពិនិត្យនិងកែសម្រួលឡជីវឧស្ម័នដែលបានសាងសង់រួចហើយ ដែលមានបញ្ហាបច្ចេកទេសនៅតាមខេត្តគោលដៅ។

### ៤.២ ការងារសុខភាពសត្វ

- **លទ្ធផលត្រួតពិនិត្យនិងបង្ក្រាបបទល្មើសសត្វនិងផលិតផលមានដើមកំណើតពីសត្វ៖** បទល្មើសសត្វនិងផលិតផលមានដើមកំណើតពីសត្វត្រូវបានត្រួតពិនិត្យ និងបង្ក្រាបយ៉ាងសកម្មដោយក្រុមអន្តរាគមន៍របស់អគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តចំនួន ១៧៣ករណី ក្នុងនោះមិនមានលិខិតអនុញ្ញាតត្រឹមត្រូវ៣០ករណី និងមានលិខិតអនុញ្ញាតត្រឹមត្រូវ១៤៣ករណី។ រាជធានី-ខេត្តចំនួន ២៥បាននិងកំពុងអនុវត្តជីវសុវត្ថិភាពដោយបានបាញ់ថ្នាំរំងាប់មេរោគចំនួន ១២៩ ៦៤៨លើក នៅតាមកសិដ្ឋានចិញ្ចឹមសត្វ ទីកន្លែងចិញ្ចឹមសត្វ សត្តឃាតដ្ឋាន ទីកន្លែងលក់បក្សី និងកន្លែងផ្ទុះជំងឺសត្វ។
- **ការងារផ្សព្វផ្សាយបច្ចេកទេស**

- ចុះប្រជុំផ្សព្វផ្សាយបច្ចេកទេសចិញ្ចឹមសត្វ និងជំងឺឆ្លងសត្វនៅតាមបណ្តាខេត្តចំនួន ៤ខេត្ត
- ចុះប្រជុំណែនាំពីជំងឺផ្តាសាយបក្សីដល់កសិករ និងអ្នកពាក់ព័ន្ធនៅតាមបណ្តាខេត្តចំនួន ៦ខេត្ត
- ចុះពិនិត្យកសិដ្ឋានចិញ្ចឹមសត្វដែលខ្វះខាតបច្ចេកទេសចិញ្ចឹមសត្វ និងការដាំដំណាំចំណីសត្វចំនួន ២គ្រួសារនៅខេត្តកំពង់ធំ
- ចុះបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមសត្វ និងបច្ចេកទេសដាំដំណាំចំណីសត្វនៅតាមបណ្តាខេត្តចំនួន ៥ខេត្ត
- ចុះផ្សព្វផ្សាយបច្ចេកទេសចិញ្ចឹមសត្វនៅតាមបណ្តាខេត្តចំនួន ៩ខេត្ត

- **ការងារនីតិកម្ម និងវិវាទ** បាននិងកំពុងរៀបចំលិខិតបទដ្ឋានគតិយុត្តមួយចំនួនទៀត។

- សម្រេចបានប្រកាសចំនួន ២ប្រកាស ទី១-ប្រកាសស្តីពីនីតិវិធីនៃការផ្តល់លិខិតអនុញ្ញាត និងកំណត់ការគ្រប់គ្រងចំណីសត្វ វត្ថុធាតុដើម ឬសារធាតុបន្ថែម ធ្វើពាណិជ្ជកម្ម ការផលិត និងធ្វើការលាយផ្សំ និងទី២-ប្រកាសស្តីពីនីតិវិធីនិងសិទ្ធិពិន័យអន្តរការណ៍លើបទល្មើសសុខភាពសត្វ និងផលិតកម្មសត្វ
- បានប្រកាសចំនួន ២ទៀតប្រជុំសម្រេចនៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទគឺប្រកាសទី១-ប្រកាសស្តីពីនីតិវិធីនៃការគ្រប់គ្រងបសុឱសថ និងវត្ថុធាតុជីវបសុព្យាបាលធ្វើពាណិជ្ជកម្ម ធ្វើការផលិត និងធ្វើការលាយផ្សំ និងទី២-ប្រកាសអន្តរក្រសួងលេខ១០១៣ រវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងលិខិតបទដ្ឋានគតិយុត្តមួយចំនួនទៀតកំពុងរៀបចំនៅអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ

- ចុះប្រជុំផ្សព្វផ្សាយកម្រងលិខិតបទដ្ឋានគតិយុត្តវិស័យសុខភាពសត្វ និងផលិតកម្មសត្វនៅតាមបណ្ដាខេត្តចំនួន ១២ខេត្ត និងបានទទួលដោះស្រាយលើបណ្ដឹងចំនួន៤។

#### ៤.៣ ការងារស្រាវជ្រាវ

- **ការងារស្រាវជ្រាវផលិតកម្ម៖** បច្ចុប្បន្ននេះនៅស្ថានីយពិសោធន៍ពូជគោភ្នំតាម៉ៅមានគោសរុបចំនួន ១១០ក្បាល។
- **ការងារស្រាវជ្រាវសុខភាពសត្វ៖** ក្នុងគោលបំណងត្រួតពិនិត្យ និងទប់ស្កាត់ការឆ្លងរាលដាលជំងឺឆ្លងសត្វបានទាន់ពេលវេលា អង្គភាពជំនាញតែងតែបានយកចិត្តទុកដាក់តាមដានស្រាវជ្រាវជំងឺសត្វតាមរយៈការចុះអង្កេតតាមដាននិងយកវត្ថុវិភាគនៅតាមកន្លែងដែលមានសត្វឈឺ និងងាប់ ឬនៅតាមសត្តឃាតដ្ឋានសរុបបានចំនួន ១៤ ០៥៣វត្ថុវិភាគ ដើម្បីធ្វើការវិភាគរកប្រភេទមេរោគបង្កជំងឺ ជាពិសេសមេរោគជំងឺផ្ដាសាយបក្សី និងជំងឺប៉េស្តជ្រូកអាហ្វ្រិក (ASF)។

## ៥ ផ្នែកជលផល

### ៥.១ អាជីវកម្មនេសាទ

៥.១.១ នេសាទទឹកសាប

- ដាយត្រីបានបញ្ចប់ត្រឹមចំនួន ១ ៥០០តោន ស្មើនឹង១២,៥០% នៃផែនការចំនួន ១២ ០០០តោន ប្រៀបធៀបនឹងឆ្នាំ២០១៩ ថយចុះចំនួន ៨៧០តោន

- នេសាទគ្រួសារក្នុងដែននេសាទអនុវត្តបានចំនួន ១៨៨ ៩០០តោន ស្មើនឹង៥៤,៧៥% នៃផែនការចំនួន ៣៤៥ ០០០តោន ប្រៀបធៀបនឹងឆ្នាំ២០១៩ ថយចុះចំនួន ៥ ១០០តោន

- នេសាទគ្រួសារតាមវាលស្រែអនុវត្តបានចំនួន ៦២ ២៤៦តោន ស្មើនឹង៤២,៩៣% នៃផែនការចំនួន ១៤៥ ០០០តោន ប្រៀបធៀបនឹងឆ្នាំ២០១៩ ថយចុះចំនួន ៣ ៦៨៤តោន។

៥.១.២ នេសាទសមុទ្រ

អនុវត្តបានចំនួន ៨៨ ៣៣០តោន ស្មើនឹង៨០,៣០% នៃផែនការចំនួន ១១០ ០០០តោន ប្រៀបធៀបនឹងឆ្នាំ២០១៩ កើនឡើងចំនួន ២៣០តោន។

### ៥.២ វារីវប្បកម្ម

- ការចិញ្ចឹមត្រីនិងបង្គាអនុវត្តបានចំនួន ២៩៦ ៥៣០តោន ស្មើនឹង៨២,៣៧% នៃផែនការចំនួន ៣៦០ ០០០តោន ប្រៀបធៀបនឹងឆ្នាំ២០១៩ កើនឡើងចំនួន ៥០ ៩៥២តោន

- ការចិញ្ចឹមក្រពើអនុវត្តបានចំនួន ២៧២ ២៩០ក្បាល ស្មើនឹង៩០,៧៦% នៃផែនការចំនួន ៣០០ ០០០ក្បាល ប្រៀបធៀបនឹងឆ្នាំ២០១៩ កើនឡើងចំនួន ១៩ ៦៩០ក្បាល

- ការភ្ញាស់កូនត្រីពូជអនុវត្តបានចំនួន ១៥៩ ៤០០ ០០០កូន ស្មើនឹង៦៦,៤២% នៃផែនការចំនួន ២៤០ ០០០ ០០០កូន ប្រៀបធៀបនឹងឆ្នាំ២០១៩ កើនឡើងចំនួនប្រមាណ ៩០០ ០០០កូន។

### ៥.៣ ការកែច្នៃផលនេសាទ

- ផលនេសាទទឹកសាបក្នុងរដូវនេសាទអនុវត្តចំនួន ៤២ ១៥០តោន ស្មើនឹង៥១,៤០% នៃផែនការចំនួន ៨២ ០០០តោន ប្រៀបធៀបនឹងឆ្នាំ២០១៩ ថយចុះចំនួន ១ ៣៥០តោន

- ផលនេសាទសមុទ្រអនុវត្តបានចំនួន ៨ ៤៩០តោន ស្មើនឹង៩៤,៣៣% នៃផែនការចំនួន ៩ ០០០តោន ប្រៀបធៀបនឹងឆ្នាំ២០១៩ កើនឡើងចំនួន ១០តោន

- ការផលិតទឹកត្រីអនុវត្តបានចំនួន ៤២ ៨០០ ០០០លីត្រ ស្មើនឹង៧៧,៨២% នៃផែនការចំនួន ៥៥ ០០០ ០០០លីត្រ ប្រៀបធៀបនឹងឆ្នាំ២០១៩ ថយចុះចំនួន ៤ ១០០ ០០០លីត្រ។

### ៥.៤ ការត្រួតពិនិត្យនិងបង្ក្រាបបទល្មើសជលផល

- សំណុំរឿងបទល្មើសជលផលមានចំនួន ២ ០២៩ករណី ប្រៀបធៀបនឹងឆ្នាំ២០១៩ ថយចុះចំនួន ១៩៣ករណី ក្នុងនោះបទល្មើសទឹកសាបចំនួន ១ ៨៥០ករណី និងសមុទ្រចំនួន ១៧៩ករណី។

### ៥.៥ ការនាំចេញផលនេសាទ

- ផលនេសាទស្រស់នាំចេញចំនួន ១ ៤៩៨តោន ស្មើនឹង៩,៩៩% នៃផែនការចំនួន ១៥ ០០០តោន ប្រៀបធៀបនឹងឆ្នាំ២០១៩ ថយចុះចំនួន ៥ ៥០២តោន

- ផលនេសាទកែច្នៃនាំចេញចំនួន ២៣២តោន ស្មើនឹង៤,៦៤% នៃផែនការចំនួន ៥ ០០០តោន ប្រៀបធៀបនឹងឆ្នាំ២០១៩ ថយចុះចំនួន ៣ ៧៤៨តោន។

### ៥.៦ ការប្រមូលថវិកា

- ចំណូលពីសេវាផ្សេងៗក្នុងផ្នែកជលផលចំនួន ៤៨៥ ១១៨ ៣៦០រៀល ស្មើនឹង១៦,២០% នៃផែនការចំនួន ២ ៩៩៤ ០០០ ០០០រៀល ប្រៀបធៀបនឹងឆ្នាំ២០១៩ កើនឡើងចំនួន ៣០ ៨៤៨ ៥៦២រៀល។

## ៦ ផ្នែកអធិការដ្ឋាន

- ចុះធ្វើអធិការកិច្ចលើការងារដឹកនាំ និងគ្រប់គ្រងរបស់វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា
- ចូលរួមជួបពិភាក្សាការងារជាមួយឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្តបាត់ដំបងលើការងារដឹកនាំរបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តបាត់ដំបង
- ចុះត្រួតពិនិត្យលើការងារដឹកនាំ គ្រប់គ្រងរបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តពោធិ៍សាត់ កំពង់ឆ្នាំង រតនគិរី មណ្ឌលគិរី កោះកុង ព្រះសីហនុ កំពង់ធំ ប៉ៃលិន បាត់ដំបង ព្រះវិហារ សៀមរាប ស្ទឹងត្រែង ក្រចេះ កែប និងខេត្តកំពត និងពិនិត្យ ជំរុញការកែលម្អចំណុចខ្វះខាតដែលក្រសួងចេញលិខិតឱ្យកែលម្អកន្លងមក
- ចូលរួមជួបពិភាក្សាការងារជាមួយឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្តតាកែវ និងថ្នាក់ដឹកនាំមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តតាកែវលើការងារដឹកនាំ និងគ្រប់គ្រងរបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តតាកែវ
- ចូលរួមជួបពិភាក្សាការងារជាមួយឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្តព្រៃវែង និងថ្នាក់ដឹកនាំមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តព្រៃវែង
- អញ្ជើញថ្នាក់ដឹកនាំមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តប៉ៃលិនធ្វើការណែនាំ និងជំរុញឱ្យអនុវត្តកែលម្អចំណុចខ្វះខាតរបស់មន្ទីរ
- ចុះពិនិត្យ និងប្រជុំពិភាក្សាជាមួយឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្ត និងសមត្ថកិច្ចពាក់ព័ន្ធពីបញ្ហាគ្រប់-គ្រងវិស័យជលផល និងព្រៃកោងកាងនៅខេត្តកែប
- បានចុះត្រួតពិនិត្យទីតាំងដីស្ថានីយបណ្តុះកូនឈើហូបផ្លែរបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តប៉ៃលិន
- បានទទួលពាក្យបណ្តឹងចំនួន ៤ករណី
- បានស្រាវជ្រាវព័ត៌មានតាមបណ្តាគេហទំព័រពាក់ព័ន្ធនឹងវិស័យកសិកម្មចំនួន ៥៨៩ករណី
- បានចូលរួមកម្មវិធីប្រជុំ សិក្ខាសាលា និងការងារសង្គមចំនួន ៧៥លើក។

## ៧ ផ្នែករដ្ឋបាល

- បានទទួលលិខិតសរុបចំនួន ៦ ៥៧៦ច្បាប់ ក្នុងនោះពីក្រសួង-ស្ថាប័ននានាចំនួន ២ ៧១១ច្បាប់ ទទួលពីអង្គភាពក្រោមឱវាទចំនួន ២ ៥៣៨ច្បាប់ ទទួលពីរាជធានី-ខេត្តចំនួន ១ ៣២៧ច្បាប់ និងបានចាត់ចែងរៀបចំលិខិតឆ្លើយតបបន្តតាមចរន្តការងាររដ្ឋបាល
- បានបញ្ជូនឯកសារ និងលិខិតទៅក្រសួង-ស្ថាប័នផ្សេងៗ អង្គភាពក្រោមឱវាទ និងរាជធានី-ខេត្តចំនួន ៨ ៦៥០ច្បាប់ ចេញប្រកាស សេចក្តីសម្រេច និងសារាចរចំនួន ៣១៨ច្បាប់ និងចម្លងផ្សព្វផ្សាយចែកទៅអង្គភាពក្រោមឱវាទបានចំនួន ១៦៩ច្បាប់
- បានបូកសរុបរបាយការណ៍របស់ក្រសួងប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ
- ថ្នាក់ដឹកនាំនាយកដ្ឋានកិច្ចការរដ្ឋបាលបានសម្របសម្រួលចាត់ចែងក្នុងពិធីផ្សេងៗ និងបានចូលរួមរាល់កិច្ចប្រជុំដើម្បីក្តាប់ឱ្យបានរាល់ការងារពាក់ព័ន្ធរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- សម្របសម្រួលក្នុងការរៀបចំចាត់ចែងកិច្ចការរដ្ឋបាលទូទៅ ពិធីការក្នុងការទទួលគណៈប្រតិភូជាតិ-អន្តរជាតិ ការរៀបចំកិច្ចប្រជុំនិងពិធីបុណ្យផ្សេងៗ ការងារសន្តិសុខសណ្តាប់ធ្នាប់រួមរបស់ក្រសួងបានល្អ ព្រមទាំងចាត់ចែងលិខិតអញ្ជើញផ្សេងៗតាម Telegram ផ្សព្វផ្សាយព័ត៌មានផ្សេងៗ តាមរយៈគេហទំព័រ www.maff.gov.kh, Facebook MAFF: ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (មជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម)។

## ៨ ផ្នែកបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស

- ក្របខ័ណ្ឌមន្ត្រីរាជការសរុបទូទាំងប្រទេសមានចំនួន ៥ ៨៦៥នាក់ (ស្រី១ ៤២១នាក់) ស្មើនឹង២៤,២២% រួមមាន៖
  - អង្គភាពថ្នាក់កណ្តាលចំនួន ២ ៩២៥នាក់ (ស្រី៨២៥នាក់) ស្មើនឹង២៨,២០%
  - អង្គភាពថ្នាក់រាជធានី-ខេត្តចំនួន ២ ៩៤០នាក់ (ស្រី៥៩៦នាក់ ស្មើនឹង២០,២៧%
- បានតែងតាំងដំឡើងឋានៈ និងផ្ទេរសម្រួលភារកិច្ចមន្ត្រីរាជការសរុបចំនួន ១១៤នាក់ (ស្រី៣៤នាក់)
- បានរៀបចំប្រកាសលុបឈ្មោះមន្ត្រីរាជការចេញពីក្របខ័ណ្ឌចំនួន២១នាក់ (ស្រី៤នាក់)
- បានរៀបចំប្រកាសផ្ទេរមន្ត្រីរាជការផ្ទៃក្នុងក្រសួងចំនួន៧១នាក់ (ស្រី១៣នាក់)
- បានរៀបចំប្រកាសផ្ទេរមន្ត្រីរាជការចេញក្រៅក្រសួងចំនួន៧នាក់ និងផ្ទេរចូលក្នុងក្រសួងចំនួន៩នាក់
- បានរៀបចំលិខិតអនុញ្ញាតច្បាប់ឈប់សម្រាកការងារមានចំនួន ៦៨នាក់ (ស្រី៤៦នាក់) ក្នុងនោះ ច្បាប់ឈប់សម្រាកព្យាបាលជំងឺចំនួន ៥នាក់ ច្បាប់ឈប់សម្រាកលំហែមាតុភាពចំនួន ២៧នាក់ ច្បាប់ឈប់សម្រាកប្រចាំឆ្នាំចំនួន ៣២នាក់ (ស្រី១៥នាក់) ច្បាប់ឈប់សម្រាកមានធុរៈផ្ទាល់ខ្លួនចំនួន ២នាក់ និងច្បាប់ឈប់សម្រាករយៈពេលខ្លីចំនួន ២នាក់

- ការងារបណ្តុះបណ្តាលក្នុង និងក្រៅប្រទេសសរុបចំនួន ១ ៦៦៣នាក់ (ស្រី៣៦៧នាក់)ក្នុងនោះ៖
  + ការបណ្តុះបណ្តាលក្នុងប្រទេសរយៈពេលខ្លី និងមធ្យមសរុបចំនួន ១ ៤៩៤នាក់ (ស្រី៣១៩នាក់)
  + ការបណ្តុះបណ្តាលក្រៅប្រទេសសរុបចំនួន ១៦៩នាក់ (ស្រី៤៨នាក់)។

## ៩ ផ្នែកផែនការ និងស្ថិតិ

- បានរៀបចំសិក្ខាសាលាស្តីពីយន្តការ នីតិវិធី សម្រាប់រៀបចំគម្រោងកម្មវិធីវិនិយោគសាធារណៈ (កវស) ៣ឆ្នាំរំកិល២០២១-២០២៣ នៅខេត្តតាកែវ និងបានបំពេញគម្រោងកម្មវិធីវិនិយោគសាធារណៈ (កវស) ៣ឆ្នាំ រំកិលនេះ ទៅក្នុងប្រព័ន្ធរបស់ក្រសួងផែនការ និងបញ្ជូនគម្រោងកម្មវិធីវិនិយោគសាធារណៈ (កវស) ៣ឆ្នាំ រំកិល ឆ្នាំ២០២១-២០២៣ ជូនទៅក្រសួងផែនការ
- បានចូលរួមចុះសម្របសម្រួល និងដឹកនាំការប្រមូលទិន្នន័យលើការសិក្សាខ្សែច្រវាក់តម្លៃផលិតផលកសិកម្មដើម្បីជំរុញទីផ្សារប្រកបដោយបរិយាប័ន្នសម្រាប់កសិករខ្នាតតូច នៅខេត្តបាត់ដំបង កំពង់ធំ សៀមរាប បន្ទាយមានជ័យ មណ្ឌលគិរី រតនគិរី កែប កំពត កោះកុង ព្រះសីហនុ ព្រះវិហារ កណ្តាល កំពង់ចាម ស្វាយរៀង តាកែវ និងខេត្តកំពង់ស្ពឺ
- បានចូលរួមចុះពិនិត្យ និងប្រមូលព័ត៌មានពាក់ព័ន្ធនឹងសំណើសុំជួយដោះស្រាយបញ្ហាដីចំនួន ៦៧០ហ.តរបស់ក្រុមហ៊ុន អិន ខេ វេនឈ័រ (ខេមបូឌា) លីមីធីត ស្ថិតនៅខេត្តស្វាយរៀង
- បានចូលរួមចុះពិនិត្យ តាមដាន និងវាយតម្លៃវឌ្ឍនភាពរបស់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចទូទាំងប្រទេស សម្រាប់ឆ្នាំ២០១៩
- បានអនុញ្ញាតជាគោលការណ៍ឱ្យមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកំពង់ឆ្នាំង បញ្ចេញស្រូវពូជចាស់អន់គុណភាពចំនួន ១០ ៦៣៣គ.ក្រ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តពោធិ៍សាត់ចំនួន ៤៤១គ.ក្រ
- បានធ្វើអង្កេតស្ទង់ទិន្នផលស្រូវស្រាលដើមរដូវឆ្នាំ២០២០ នៅខេត្តស្វាយរៀង និងខេត្តបន្ទាយមានជ័យ
- បានចុះស្រង់ទិន្នន័យតម្លៃទីផ្សារកសិផលទូទាំង២៥ រាជធានី-ខេត្ត
- បានចុះសម្របសម្រួលនិងដឹកនាំការប្រមូលទិន្នន័យលើការសិក្សាខ្សែច្រវាក់តម្លៃផលិតផលកសិកម្មដើម្បីជំរុញទីផ្សារប្រកបដោយបរិយាប័ន្នសម្រាប់កសិករខ្នាតតូច។

## ១០ ផ្នែកគណនេយ្យ ហិរញ្ញវត្ថុ

- បានអនុវត្តប្រមូលចំណូលនូវទឹកប្រាក់សរុបចំនួន ៣ ៧០៤ ១៩៣ ២៥៣រៀល
- អង្គភាពប្រមូលចំណូលទាំង៦ចុះប្រតិបត្តិការចំណូលក្នុងប្រព័ន្ធ NRMIS សរុបទឹកប្រាក់ចំនួន២ ៨៨៧ ៧៨៨ ១០៤រៀល
- បានបញ្ចេញអាណត្តិបើកប្រាក់ពីក្រសួងសរុបចំនួន ៩៥០ ៣៤៦ ៧០២រៀល
- បានចូលរួមចុះត្រួតពិនិត្យ និងវាយតម្លៃប្រគល់-ទទួលស្តីពីការងារបោះបង្គោលព្រំប្រទល់ការពារព្រៃលិចទឹកបង្គោលអភិរក្សជលផល បង្គោលកំណត់ព្រំប្រទល់ព្រៃកោងកាង ទម្លាក់ប្រអប់បេតុង និងរៀបចំស្លាក់ការល្បាត ប្រចាំឆ្នាំ២០២០ នៅខេត្តពោធិ៍សាត់ បន្ទាយមានជ័យ កំពង់ឆ្នាំង កំពង់ចាម ត្បូងឃ្មុំ កំពង់ធំ សៀមរាប តាកែវ និងខេត្តកែប
- បានរៀបចំលិខិតសំណើសុំគោលការណ៍ធានាចំណាយឥណទានថវិកាជំពូក២១ ចំនួន ១៧ ២២៦ ៣៦៨ ០០០រៀល និងថវិកាបុរេប្រទានចំនួន ៤០% សម្រាប់វិនិយោគលើហេដ្ឋារចនាសម្ព័ន្ធស្រោចស្រពនៅតាមបណ្តាសហគមន៍កសិកម្មស្ថិតនៅខេត្តកំពង់ចាម ព្រៃវែង និងខេត្តកំពង់ឆ្នាំង
- បានរៀបចំលិខិតជូនដំណឹងស្តីពីកាតព្វកិច្ចបង់ថ្លៃសម្បទានដីសេដ្ឋកិច្ចជូនក្រុមហ៊ុនចំនួន ៨ក្រុមហ៊ុន
- បានចុះបិទបញ្ជីប្រគល់ទទួលចំណូល ចំណាយថវិកា និងទ្រព្យសម្បត្តិរដ្ឋ សម្រាប់ការផ្ទេរតំណែងប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តស្វាយរៀង។

## ១១ ផ្នែកសវនកម្មផ្ទៃក្នុង

- បានរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋឆ្នាំ២០១៩ និងធ្វើការបែងចែកសម្ភារការិយាល័យ សង្ហារិម សម្ភារបរិក្ខាបច្ចេកទេស ថែទាំ ជួលជុល និងផ្គត់ផ្គង់សម្រាប់បម្រើការងារពុំមានការរាំងស្ទះ
- បានរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២១-២០២៣ ផែនការថវិកាឆ្នាំ២០២១ ផែនការលទ្ធកម្មសាធារណៈឆ្នាំ២០២១ និងផែនការរជ្ជទេយ្យបុរេប្រទានឆ្នាំ២០២១
- បានរៀបចំរបាយការណ៍តាមដាន និងវាយតម្លៃការអនុវត្តថវិកាកម្មវិធីតាមទម្រង់ M1 ប្រចាំត្រីមាស និងរបាយ-ការណ៍សមិទ្ធកម្មប្រចាំឆមាសទី១
- បានចុះធ្វើសវនកម្មតាមផែនការសកម្មភាពសវនកម្មផ្ទៃក្នុងបានចំនួន ១សវនដ្ឋាន នៅមជ្ឈមណ្ឌលព័ត៌មាន និងឯក-សារកសិកម្ម

- បានចុះធ្វើសវនកម្មចំនួន ២៨សវនដ្ឋាន ស្មើនឹង៥៣,៨៤% នៃផែនការចំនួន ៥២សវនដ្ឋាន ដោយរកឃើញលទ្ធផលសវនកម្ម និងផ្តល់អនុសាស្ត្រសម្រាប់សវនដ្ឋានកែលម្អលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងចំនួន ១២៨អនុសាសន៍ និងការអនុវត្តអនុសាសន៍គ្រាមុនរបស់សវនដ្ឋានសម្រេចបានចំនួន ៥៩,៩១% នៃផែនការចំនួន ៥២%។

## ១២ ផ្នែកសហប្រតិបត្តិការអន្តរជាតិ

- ទទួលជួបភ្ញៀវស្ថានទូតចំនួន ៣លើក និងវិស័យឯកជនចំនួន ២លើក
- បានចូលរួមប្រជុំចំនួន ៧លើក សិក្ខាសាលាចំនួន ១លើក ទស្សនកិច្ចចំនួន ២លើក សន្និសីទចំនួន ១លើក ក្រោមក្របខ័ណ្ឌទ្វេភាគី និងពហុភាគី និងបានចូលរួមប្រជុំចំនួន ៦លើក ក្រោមក្របខ័ណ្ឌអាស៊ាន
- បានចូលរួមសិក្ខាសាលាចំនួន ៥លើក វគ្គបណ្តុះបណ្តាលចំនួន ១០លើក ក្រោមក្របខ័ណ្ឌទ្វេភាគី និងពហុភាគី និងចូលរួមសិក្ខាសាលាចំនួន ៥លើក វគ្គបណ្តុះបណ្តាលចំនួន ១លើក ក្រោមក្របខ័ណ្ឌអាស៊ានលើការងារក្រៅប្រទេស
- បានសម្របសម្រួលរៀបចំកិច្ចប្រជុំចំនួន ៦លើក ទិវាចំនួន ២លើក និងវគ្គបណ្តុះបណ្តាលចំនួន ២លើកលើការងារក្នុងប្រទេស
- បានចុះអនុស្សរណៈយោគយល់គ្នាជាមួយប្រទេសចិនស្តីពី Technical Cooperation and Join Reserch on Integrated Water Resource Management and Development in Cambodia
- បានចុះអនុស្សរណៈយោគយល់គ្នាជាមួយប្រទេសកូរ៉េស្តីពី Research and Development of Hemorrhagic Septicemia (HS) Vaccines in Cambodia សម្រាប់អនុវត្តក្នុងឆ្នាំ២០២១
- បានចុះអនុស្សរណៈយោគយល់គ្នាជាមួយក្រុមហ៊ុន Yamato Green ប្រទេសជប៉ុនស្តីពី Safe vegitable Development for Domestic Market and Export
- បានចុះអនុស្សរណៈយោគយល់គ្នាជាមួយ Dana Asia ស្តីពីមជ្ឈមណ្ឌលខ្មែរ-ជប៉ុនបណ្តុះបណ្តាលចិញ្ចឹមមាន់
- បានចុះអនុស្សរណៈយោគយល់គ្នាជាមួយ FAO ស្តីពីការពង្រឹងសមត្ថភាពស្ថាប័ន និងសមត្ថភាពបច្ចេកទេសផ្តោតលើអាហារមានសុវត្ថិភាពតាមរយៈការអនុវត្តវិធានការសុវត្ថិភាពអាហារ និងការផ្តល់លិខិតបញ្ជាក់កសិផលនៅកម្ពុជា។

## ១៣ ផ្នែកនីតិកម្មកសិកម្ម

### ១៣.១ ការងារអាជីវកម្មជី-ថ្នាំកសិកម្ម

- ផ្តល់វិញ្ញាបនបត្របញ្ជាក់បញ្ជិកាថ្នាំកសិកម្ម និងជីកសិកម្មចំនួន ១៨២ក្រុមហ៊ុន សរុបចំនួន ២ ០០៥មុខ
- ផ្តល់លិខិតអនុញ្ញាតនាំចូលថ្នាំកសិកម្ម និងជីកសិកម្មចំនួន ១៩១ក្រុមហ៊ុន
- ផ្តល់វិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីឃ្លាំងសន្និធិថ្នាំកសិកម្ម និងជីកសិកម្មចំនួន ៦០ក្រុមហ៊ុន
- ចេញលិខិតអនុញ្ញាតផ្គត់ផ្គង់ចែកចាយថ្នាំកសិកម្ម និងជីកសិកម្មចំនួន ៥៤ក្រុមហ៊ុន
- ចេញលិខិតអនុញ្ញាតប្រតិបត្តិការលាយផ្សំ ឬវេចខ្ចប់ជាថ្មីថ្នាំកសិកម្ម និងជីកសិកម្មចំនួន ៩ក្រុមហ៊ុន
- ផ្តល់លិខិតអនុញ្ញាតនាំចេញថ្នាំកសិកម្មចំនួន ១ក្រុមហ៊ុន។

### ១៣.២ ការងារមន្ទីរពិសោធន៍

ធ្វើវិភាគរកសារធាតុបន្ទាប់បន្សំ និងលោហៈធ្ងន់នៅក្នុងសមាសភាពផ្សំនៃជីកសិកម្មដែលស្នើសុំវិភាគចំនួន ៥៦ក្រុមហ៊ុន សរុបចំនួន ៤០៦សំណាក។

### ១៣.៣ ការងារអភិវឌ្ឍបទដ្ឋានគតិយុត្ត

- បានប្រកាសអន្តរក្រសួងស្តីពីគោលការណ៍ណែនាំវិធានសុវត្ថិភាពក្នុងការប្រើប្រាស់ថ្នាំកសិកម្ម ការបោះសំណល់ពីការប្រើប្រាស់ថ្នាំកសិកម្ម និងសំបកវេចខ្ចប់ថ្នាំកសិកម្ម
- បានពិនិត្យផ្តល់មតិចំពោះករណីផ្សេងៗចំនួន ១៨ករណី
- បានពិនិត្យផ្តល់មតិលើសំណើសុំគោលការណ៍ផ្សព្វផ្សាយធ្វើសិក្ខាសាលាបណ្តុះបណ្តាលដល់អាជីវករលក់សម្ភារកសិកម្ម របៀបប្រើប្រាស់ផលិតផលថ្នាំកសិកម្ម និងជីកសិកម្មប្រកបដោយសុវត្ថិភាពខ្ពស់តាមរយៈស្ថានីយវិទ្យុ និងទូរទស្សន៍នៅតាមបណ្តារាជធានី-ខេត្តជូនក្រុមហ៊ុនចំនួន ៧ក្រុមហ៊ុន
- បានរៀបចំសិក្ខាសាលាស្តីពីការផ្សព្វផ្សាយពីនីតិវិធី និងវិធានបច្ចេកទេសនៃការធ្វើពាណិជ្ជកម្មថ្នាំកសិកម្ម និងជីកសិកម្មនៅខេត្តកំពតមានអ្នកចូលរួមចំនួន ១៣៣នាក់
- បានបើកវគ្គអប់រំសមត្ថភាពវិជ្ជាជីវៈដល់អាជីវករអ្នកលក់ដុំលក់រាយថ្នាំកសិកម្ម និងជីកសិកម្មចំនួន ៥ខេត្ត នៅ

ខេត្តបន្ទាយមានជ័យ ឧត្តរមានជ័យ រតនគិរី កំពង់ធំ និងខេត្តបាត់ដំបងមានអ្នកចូលរួមចំនួន ៣៤៦នាក់។

**១៣.៤ ការងារអនុវត្តច្បាប់**

- បានចុះធ្វើអធិការកិច្ចត្រួតពិនិត្យបទល្មើសថ្នាំកសិកម្ម និងជីកសិកម្មខេត្តគោលដៅចំនួន ១៣ខេត្ត គឺខេត្តសៀមរាប បន្ទាយមានជ័យ ប៉ៃលិន បាត់ដំបង កណ្តាល ឧត្តរមានជ័យ ព្រះវិហារ តាកែវ មណ្ឌលគិរី រតនគិរី កំពង់ចាម កំពត និងខេត្តកំពង់ធំ លើដេប៉ូចំនួន ៨៦ដេប៉ូ សម្រេចពិន័យអន្តរការណ៍ ២១ករណី

- បានធ្វើការពិន័យអន្តរការណ៍ជាប្រាក់ចំពោះក្រុមហ៊ុនពាណិជ្ជកម្មថ្នាំកសិកម្ម និងជីកសិកម្មដែលខកខានពុំបានប្រកាសប្រតិវេទន៍ស្តីពីការនាំចូលថ្នាំកសិកម្ម និងជីកសិកម្មចំនួន ៥ក្រុមហ៊ុន។

## ១៤ ផ្នែកមជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម

- បានថែទាំលើគេហទំព័រ (Web) និង Mobile App របស់ក្រសួង និងអង្គភាពក្រោមឱវាទក្រសួងសរុបចំនួន ១៧ (១៦គេហទំព័រ និង១កម្មវិធី) និងគេហទំព័រមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត

- បញ្ចូលតំណរភ្ជាប់គេហទំព័ររបស់នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅក្នុងគេហទំព័រក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានបង្កើត នឹងដាក់ឱ្យដំណើរការកម្មវិធីទូរសព្ទដៃឆ្លាតវៃ (Android Mobile App) ដែលមានឈ្មោះថា AgriLibrary របស់បណ្ណាល័យកសិកម្ម

- បានតាមដានទិន្នន័យ និងសម្អាត Catch នៅលើ Cloud Server នៃគេហទំព័រទាំង៤១ (ក្រសួង អគ្គនាយក នាយកដ្ឋាន និងមន្ទីររាជធានី-ខេត្ត)

- ការធ្វើបច្ចុប្បន្នភាពគេហទំព័រ និងចុះបណ្តុះបណ្តាល តាមដានការប្រើប្រាស់ និងបង្ហាញមុខងារប្រើប្រាស់ថ្មីៗលើគេហទំព័ររបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តចំនួន ៧ដូចជាខេត្តសៀមរាប កំពង់ធំ កំពង់ស្ពឺ កោះកុង តាកែវ ព្រះសីហនុ និងខេត្តរតនគិរី

- ចុះប្រមូលទីតាំងដំណាំស្រូវប្រាំងចំនួន ៣ខេត្ត គឺ ខេត្តស្វាយរៀង តាកែវ និងខេត្តព្រៃវែង ដើម្បីរៀបចំផែនទីដំណាំកសិកម្មសម្រាប់បញ្ចូលក្នុងគេហទំព័រព័ត៌មានភូមិសាស្ត្រកសិកម្ម

- បន្តការធ្វើបច្ចុប្បន្នភាពលើគេហទំព័របណ្ណាល័យកសិកម្ម និងជំរុញការផ្សព្វផ្សាយ និងបណ្តុះបណ្តាលការប្រើ-ប្រាស់អំពីគេហទំព័របណ្ណាល័យកសិកម្ម និងពិនិត្យអំពីការរៀបចំបណ្ណាល័យរបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តចំនួន ៥ ដូចជាខេត្តព្រះវិហារ ក្រចេះ សៀមរាប កណ្តាល និងខេត្តស្វាយរៀង។

## ១៥ ផ្នែកផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានចុះទៅថត Video បទយកការណ៍នៅខេត្តក្រចេះ និងខេត្តសៀមរាបចំនួន ១៥ប្រធានបទ គឺ ដំណាំការ៉ុតស្ពៃក្តោប ទំពាំងផ្អែម ការចិញ្ចឹមមាន់ភ្នាស់យកកូនលក់ រុក្ខជាតិលម្អ ការដាំត្រសក់ ការចិញ្ចឹមកន្លាយ ដាំបន្លែប្រើប្រព័ន្ធដំណក់ទឹក ជីវភាពរីកចម្រើនដោយមុខរបរការចិញ្ចឹមមាន់ បន្លែគ្រីនបេប៊ីលីស ការចងក្រងបណ្តុំបន្លែសុវត្ថិភាព ការចិញ្ចឹម-មាន់តាមបច្ចេកទេសថ្មី មុខរបរចិញ្ចឹមត្រីប្រា និងការដាំបន្លែតាមបច្ចេកទេសកសិកម្មធន់នឹងការប្រែប្រួលអាកាសធាតុ

- បានចុះផលិតនាទីចុះស្រែជាមួយកសិករចំនួន ១៤ប្រធានបទ គឺ បច្ចេកទេសចិញ្ចឹមមាន់បន្សាំទៅនឹងការប្រែ-ប្រួលអាកាសធាតុ ដាំបន្លែបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ បណ្តុំកសិករចិញ្ចឹមមាន់តាមតម្រូវការទីផ្សារ បណ្តុំកសិករដាំដំណាំស្លឹកខ្ទឹម ដំណាំបន្លែផ្ទះសំណាញ់ ដាំបន្លែប្រើប្រព័ន្ធដំណក់ទឹក ការចិញ្ចឹមគោបំប៉ន ចងក្រងបណ្តុំកសិករចិញ្ចឹមមាន់ បច្ចេកទេសដាំដំឡូង បច្ចេកទេសចិញ្ចឹមទាយកពង

- បានបញ្ជូនអត្ថបទបច្ចេកទេសកសិកម្មចំនួន ៥៤ដើម្បីចាក់ផ្សាយ

- បានផ្សព្វផ្សាយកសិកម្មតាមប្រព័ន្ធសេវាព័ត៌មានវិទ្យាពីអត្ថបទបច្ចេកទេសកសិកម្មចំនួន ១៥៥អត្ថបទ

- ចូលរួមចុះរៀបចំជ្រើសរើសទីកន្លែងសម្រាប់ការធ្វើបង្ហាញបច្ចេកទេសដាំបន្លែនៅទីតាំងដីសម្បទានសង្គមកិច្ចភូមិសុខសែនជ័យ ខេត្តកំពង់ឆ្នាំង។

## ១៦ ផ្នែកកសិ-ឧស្សាហកម្ម

- បានរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍កសិ-ឧស្សាហកម្មកម្ពុជាឆ្នាំ២០១៩-២០៣០ និងបានបោះពុម្ពផ្សព្វផ្សាយជូនអង្គភាពពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍នានា

- បាននិងកំពុងបន្តរៀបចំសេចក្តីព្រាងច្បាប់ស្តីពីផលិតកម្មកសិកម្មតាមកិច្ចសន្យា ប្រជុំពិភាក្សាលើសេចក្តីព្រាងច្បាប់នេះចំនួន ១៦លើក

- បានចុះសិក្សាពីសក្តានុពលដំណាំបន្លែផ្លែឈើ ជាពិសេសបន្លែសរីរាង្គ និងការវិភាគគុណភាពទឹកក្រោមដីសម្រាប់ប្រើប្រាស់ និងផ្សព្វផ្សាយពីផលប្រយោជន៍នៃការផលិតមានផែនការឆ្លើយតបម្រូវការទីផ្សារតាមយន្តការកិច្ចសន្យាផលិតកម្មកសិកម្ម

- បានសហការជាមួយក្រុមហ៊ុន Top Planning Japan លើការសិក្សាខ្សែច្រវាក់ស្វាយចន្ទីលើខេត្តគោលដៅចំនួន ៤ខេត្ត គឺ ខេត្តកំពង់ធំ កំពង់ចាម សៀមរាប និងខេត្តព្រះវិហារ និងសិក្សាគម្រោងសាកល្បងជាមួយសិប្បកម្មកែច្នៃគ្រាប់ស្វាយចន្ទីជ័យសំបូរ ខេត្តកំពង់ធំ

- បានចុះសិក្សា និងប្រមូលទិន្នន័យបឋមអំពីខ្សែច្រវាក់តម្លៃផលិតផលម្រេចនៅខេត្តព្រះវិហារ

- បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពីវិធីសាស្ត្រថ្មីៗនៃការវិភាគគុណភាព សុវត្ថិភាពផលិតផលកសិកម្ម និងចំណីអាហារនៅមន្ទីរពិសោធន៍ផលិតផលកសិកម្ម និងចំណីអាហារកម្ពុជា

- បានចុះបណ្តុះបណ្តាលកសិករស្តីពីបច្ចេកទេសក្រោយការប្រមូលផលនៃផលិតផលកសិកម្មនៅខេត្តស្ទឹងត្រែង និងខេត្តក្រចេះ

- បានចុះបណ្តុះបណ្តាលកសិករស្តីពីបច្ចេកទេសកែច្នៃបន្លែ ផ្លែឈើ និងគ្រាប់ធញ្ញជាតិនៅខេត្តកំពត និងខេត្តត្បូងឃ្មុំ

- បានកសាងគម្រោងវិភាគកាកសំណល់គីមី ថ្នាំកសិកម្ម លោហៈធ្ងន់ មីកូតុកស៊ីន និងសារធាតុពុលផ្សេងៗទៀតក្នុងផលិតកម្មកសិកម្ម និងចំណីអាហារ

- បានវិភាគរកសមាសធាតុគីមី លោហៈធ្ងន់ គុណភាព និងអាហារូបត្ថម្ភនៅក្នុងផលិតផលកសិកម្មម្សៅ អង្ករពោតលឿង ទឹកឃ្មុំ បន្លែស្រស់

- បានវិភាគរកសមាសធាតុ អាស៊ូត ផូស្វ័រ និងប៉ូតាស្យូមនៅក្នុងជីលាមកសត្វ ជីកាកឡ ទឹកស្ងោរគ្រាប់ស្វាយចន្ទី និងកាកសំណល់ផ្ទះបាយ។

## ១៧ ការស្រាវជ្រាវ ការអប់រំ និងការបណ្តុះបណ្តាលកសិកម្ម

### ១៧.១ វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា

- បានបន្តការអភិរក្សពូជដំណាំចំនួន ៣៨ប្រភេទ រួមមានស្រូវចំនួន ៦ ៧៧៦បញ្ជីក/សំណាក និងដំណាំផ្សេងៗចំនួន ៣៧ប្រភេទ សរុបចំនួន ២ ៣៤០បញ្ជីក/សំណាក សរុបទាំងអស់ចំនួន ៩ ១១៦បញ្ជីក/សំណាក

- បានដាំវាយតម្លៃ និងកំណត់លក្ខណៈលើដំណាំពីរមុខគឺ ដំណាំល្ពៅចំនួន ១២សំណាក និងសណ្តែកព្រៃចំនួន ៥០សំណាក

- បានដាំវាយតម្លៃប្រភេទពូជម្ទេស និងត្រសក់ស្រូវដែលទើបប្រមូលចំនួន ៩០ពូជ និងកំពុងពិនិត្យបង្ហើយសៀវភៅកាតាឡុកម្ទេសទី១ និងបោះពុម្ពនៅពេលក្រោយ

- បានធ្វើពិសោធចំនួន ១០៨ប្រភេទ នៅ៥១៨កន្លែងនៅក្នុងនោះមានពិសោធបន្សាំពូជលើស្រែកសិករ និងស្រែបង្ហាញចំនួន ៣៦៦កន្លែង។ ធ្វើទិវាស្រែបង្ហាញចំនួន ១១លើក មានកសិករចូលរួមចំនួន ៤៤១នាក់ (ស្រី ២១៨នាក់) និងបានបើកវគ្គបណ្តុះបណ្តាលកសិករចំនួន ២១លើក មានកសិករចូលរួមចំនួន ៧៨៦នាក់ (ស្រី៤៧៣នាក់)

- បានបើកវគ្គបណ្តុះបណ្តាលចំនួន ១វគ្គដែលមានអ្នកចូលរួមសរុបចំនួន ២៦នាក់ ដឹកនាំនិស្សិតចុះធ្វើកម្មសិក្សាសរសេរសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រចំនួន ៩នាក់ (ស្រី៣នាក់) មកពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញ សាកលវិទ្យាល័យអន្តរជាតិ សាកលវិទ្យាល័យស្វាយរៀង និងវិទ្យាស្ថានសន្តប៉ូល

- បានចូលរួមវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងសន្និបាតក្រៅប្រទេសចំនួន ១លើក ដែលមានថ្នាក់ដឹកនាំនិងមន្ត្រីវិទ្យាស្ថានចូលរួមចំនួន ២នាក់។ មានមន្ត្រីសរុបចំនួន ៤នាក់ទៀតបាននិងកំពុងបន្តការសិក្សាថ្នាក់បណ្ឌិតចំនួន ២នាក់ និងបរិញ្ញាបត្រ ជាន់ខ្ពស់ចំនួន ២នាក់ នៅប្រទេសកូរ៉េ ជប៉ុន និងចិន

- បានចូលរួមសរសេរអត្ថបទវិទ្យាសាស្ត្រ និងត្រូវបានទទួលឲ្យបោះពុម្ពក្នុងទស្សនាវដ្តីវិទ្យាសាស្ត្រអន្តរជាតិបានចំនួន ២អត្ថបទ

- បានបោះពុម្ពឯកសារឡើងវិញចំនួន ២០ ២២០ច្បាប់ និងបែងចែកឯកសារចំនួន ៨ ៩៣៩ច្បាប់។ អ្នកប្រើប្រាស់ព័ត៌មានបច្ចេកវិទ្យារបស់វិទ្យាស្ថានតាមរយៈគេហទំព័រ http://www.cardi.org.kh សរុប ១ ១៩៤ ០៧៦នាក់ ដោយគិតជាមធ្យមមានប្រមាណ ៤ ៩៧៥នាក់/ថ្ងៃ។

### ១៧.២ សាកលវិទ្យាល័យភូមិន្ទកសិកម្ម

- និស្សិតកំពុងសិក្សាក្នុងឆ្នាំសិក្សា២០១៩-២០២០ សរុបចំនួន ៣ ២៥៦នាក់ ចែកចេញជា១០ មហាវិទ្យាល័យ គឺៈ មហាវិទ្យាល័យវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រព្រៃឈើ វិស្វកម្មកសិកម្ម វិទ្យាសាស្ត្រជលផល កសិ-ឧស្សាហកម្ម សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ រៀបចំដែនដីនិងរដ្ឋបាលដីធ្លី និងមហាវិទ្យាល័យវិទ្យា-សាស្ត្រកៅស៊ូ និងសាលាក្រោយឧត្តម

- ចូលរួមជាវាគ្មិនពិសេសក្នុងវេទិកាស្តីពីតួនាទីរបស់អង្គការសង្គមស៊ីវិលក្នុងការទប់ស្កាត់ជំងឺកូវីដ១៩ និងការលើកកម្ពស់សេដ្ឋកិច្ចគ្រួសារតាមរយៈការអនុវត្តនូវកសិកម្មសមស្របនៅខេត្តប៉ៃលិន បាត់ដំបង បន្ទាយមានជ័យ ឧត្តរមានជ័យ និងខេត្តសៀមរាប

- បានចូលរួមធ្វើបទបង្ហាញ និងចែករំលែកបទពិសោធន៍ ក្នុងសិក្ខាសាលាស្តីពីការគ្រប់គ្រងតាមសាលារៀនលើកទី៤នៃគម្រោងកែលម្អការអប់រំមធ្យមសិក្សា (SEIP) ក្នុងគោលបំណងតភ្ជាប់ការអនុវត្តកម្មវិធីបំណិនរកចំណូលរវាងអនុ-វិស័យឧត្តមសិក្សា និងមធ្យមសិក្សា

- បានបណ្តុះបណ្តាលយុវជនកូរ៉េស្តីពីការរៀបចំគម្រោង រៀបចំផែនការអាជីវកម្ម និងចូលរួមបង្កើតកម្មវិធីជួយកសិករលក់ផលិតផលបន្លែសរីរាង្គនៅក្នុងគម្រោង INNOCAMP គាំទ្រដោយ KOICA and the Bridge International Organization

- បានចុះប្រមូលទិន្នន័យអំពីការផលិតការប្រើប្រាស់ និងទីផ្សារកាកសំណល់កសិកម្ម នៅខេត្តកំពង់ឆ្នាំង កំពង់ស្ពឺ និងខេត្តតាកែវ

- បានប្រមូលទិន្នន័យនៅខេត្តកណ្តាលរបស់គម្រោង Doubt-UvA ដោយផ្តោតលើប្រធានបទ ខ្សែច្រវាក់ផលិតកម្មនៃដំណាំស្វាយនៅស្រុកលើកដែក និងផលប៉ះពាល់នៃបម្រែបម្រួលទឹកជំនន់ទន្លេមេគង្គ ទៅលើប្រព័ន្ធដំណាំកសិកម្មតាមតំបន់ព្រែក ខេត្តកណ្តាល។

### ១៧.៣ វិទ្យាស្ថានជាតិកសិកម្មព្រែកលៀប

- និស្សិតដែលកំពុងសិក្សាសម្រាប់ឆ្នាំសិក្សា២០១៩-២០២០ សរុបចំនួន ១ ២៦៤នាក់ (ស្រី៥៤០នាក់) លើជំនាញៈ កសិកម្ម វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ វិស្វកម្មកសិកម្ម ព្រៃឈើ ជលផល សាកវប្បកម្ម សុរិយោដីនិងការគ្រប់គ្រងដី ផ្សព្វផ្សាយនិងអភិវឌ្ឍន៍ជនបទ សេដ្ឋកិច្ចកសិកម្ម មីក្រូហិរញ្ញវត្ថុ កែច្នៃអាហារ កុំព្យូទ័រ សេដ្ឋកិច្ចនយោបាយនិងស្បៀង និងភាសាអង់គ្លេស

- បានរៀបចំពិធីការពារសារណា និងប្រឡងបញ្ចប់ការសិក្សាថ្នាក់បរិញ្ញា និងបរិញ្ញារង ដោយជោគជ័យ

- បានប្រជុំគ្រប់ដេប៉ាតឺម៉ង់ចំនួន១៣លើក ដោយលើកយកកម្មវិធីសិក្សាថ្នាក់បរិញ្ញា និងបរិញ្ញារងមកពិនិត្យកែលម្អគម្រោងមុខវិជ្ជានីមួយៗ និងពិនិត្យច្របាច់បញ្ចូលគ្នានូវមុខវិជ្ជាប្រហាក់ប្រហែលគ្នាដើម្បីឲ្យចំនួនម៉ោងបង្រៀនថយចុះ និងបង្កើនជំនាញថ្មីមួយចំនួនទៀត

- បានប្រជុំដើម្បីពិនិត្យកែលម្អកម្មវិធីសិក្សាថ្នាក់បរិញ្ញាជាន់ខ្ពស់ បរិញ្ញា និងបរិញ្ញារងជាលើកចុងក្រោយ

- បានទៅទស្សនកិច្ចកសិដ្ឋានចិញ្ចឹមគោយកទឹកដោះខេត្តព្រះវិហារ១លើក

- បានពិនិត្យតាមដាន និងដំណើរការដាំដំណាំពិសោធន៍សាគូពងពស់ ស្មៅ និងព្រីងនៅស្ថានីយពិសោធន៍កសិកម្មត្រាំកក់ ខេត្តតាកែវ

- បន្តការស្រាវជ្រាវលើ ផ្កាអ័រគីដេ ចេក ស្វាយចន្ទី ត្រី

- បានណែនាំកសិករអំពីបច្ចេកទេសកសិកម្ម និងចែកពូជព្រីងម៉ាឡេស៊ី ជូនប្រជាកសិករនៅស្រុកកំពង់សិលា ខេត្តព្រះសីហនុ។

### ១៧.៤ វិទ្យាស្ថានជាតិកសិកម្មកំពង់ចាម

- និស្សិតដែលកំពុងសិក្សាក្នុងឆ្នាំ២០១៩-២០២០ សរុបចំនួន ៦៥៦នាក់ (ស្រី២៨៦នាក់) លើជំនាញវិទ្យាសាស្ត្រកសិកម្ម ក្សេត្រសាស្ត្រ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ដំណាំកៅស៊ូ សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ

- បានបញ្ជូននិស្សិតជំនាញវិទ្យាសាស្ត្រកសិកម្មឆ្នាំទី៤ ចំនួន៣នាក់ និងមន្ត្រីចំនួន១នាក់ ចូលរួមជាមួយគម្រោង ERECON លើការងារផ្សព្វផ្សាយបច្ចេកទេសកសិកម្មនិរន្តរភាព

- ពិសោធន៍លើជីសរីរាង្គពីការលូតលាស់ដំណាំបន្លែស្ពៃក្រញាញ់

- ពិសោធន៍តាមដានការបំផ្លាញរបស់កត្តាចង្រៃលើដំណាំខាត់ណាផ្កា

- ពិសោធន៍សាកល្បងផលិតមេជី Lacto Bacellus និងពិសោធន៍ឥទ្ធិពលមេជីលើការលូតលាស់ដំណាំស្ពៃក្តោប និងស្រូវនៅស្រុកកំពង់សៀម ខេត្តកំពង់ចាម

- បានធ្វើការបង្កាត់ពូជកង្កែប និងត្រីទីឡាព្យ៉ាក្រហមនៅស្ថានីយពិសោធន៍ជលផលនៃវិទ្យាស្ថានជាតិកសិកម្មកំពង់ចាម

- បានធ្វើការពិសោធន៍លើការចិញ្ចឹមបង្កងពូជអូស្ត្រាលីចំនួន ១៦៥គូ និង២៥០កូន នៅស្ថានីយពិសោធន៍ជលផលនៃវិទ្យាស្ថានជាតិកសិកម្ម កំពង់ចាម

- បានចូលរួមបណ្តុះបណ្តាលកសិករជាមួយដៃគូរបស់ក្រុមហ៊ុន និងធ្វើការស្រាវជ្រាវរួមគ្នាអំពីការកែច្នៃកសិផលលើដំណាំស្វាយចន្ទី ល្ហុង ល្ពៅ ក្រូចថ្លុង ស្លឹកគ្រៃ និងម្រេច

- សហការជាមួយ DTRA (Defence Threat Reduction Agency) ក្នុងការបើកវគ្គបណ្តុះបណ្តាលចំនួន ៣វគ្គ ដូចជាជំងឺប៉ារ៉ាស៊ីតសត្វឆ្លងមកមនុស្សនៅកម្ពុជា អេពីដេមីសាស្ត្រនៃជំងឺផ្តាសាយបក្សី ជីវសុវត្ថិភាពសម្រាប់ជំងឺហ្សូណូស និងជំងឺសត្វឆ្លងដែនដល់និស្សិតជំនាញវិទ្យាសាស្ត្រ និងវេជ្ជសាស្ត្រនៅវិទ្យាស្ថានជាតិកសិកម្មកំពង់ចាម។

### ១៧.៥ ការងារវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា

- បានស្រង់ទិន្នន័យជ័រកៅស៊ូឡូតិ៍ពិសោធន៍ក្លូន IRAA01-IRAA10, SSCT01 និង GSET02
- ថែទាំកូនកៅស៊ូស៊ីដលីងច្បារបង្កាត់ពូជ និង GSET02
- ត្រួតពិនិត្យការចៀរជ័រ និងការសាប្រមូលផលទឹកជ័រតាមពិធីពិសោធន៍គ្រប់ចម្ការពិសោធន៍
- ចុះស្រង់ទិន្នន័យជ័រកៅស៊ូនៅចម្ការពិសោធន៍សក្តានុពលទិន្នផលនៃប្រព័ន្ធចៀរជ័រចង្វាក់ d4 ចំនួន ៩ចម្ការពិសោធន៍ និងចម្ការពិសោធន៍ប្រព័ន្ធចៀរជ័រចង្វាក់រង្វើល (d3 d4 d5 d6) ចំនួន ២ចម្ការពិសោធន៍
- ត្រួតពិនិត្យការប្រមូលផលទឹកជ័រនៅចម្ការពិសោធន៍
- អនុវត្តការថែទាំកូនកៅស៊ូនៅថ្នាលបណ្តុះកូនឆ្នាំ២០២០-២០២១
- ថែទាំកូនកៅស៊ូស្ទមក្នុងបំពង់ Root Trainer ក្លូន PMB1, GT1 និង IRCA230
- វាស់ទំហំដើមសម្រាប់បើកមុខចៀរថ្មី និងរៀបចំសម្ភារបំពាក់ដើម
- ថែទាំឡូតិ៍កៅស៊ូចៀរជ័រដូចជាលាបថ្នាំរំញោច និងលាបខ្លាញ់គោលើដើមកៅស៊ូចៀរជ័រ
- ត្រួតពិនិត្យសម្ភារ និងឧបករណ៍មន្ទីរពិសោធន៍ជាតិយថាប្រភេទ។

## III-សេចក្តីសន្និដ្ឋាន និងវាយតម្លៃ

មកទល់ពេលនេះ ការងារបង្កបង្កើនផលស្រូវរដូវវស្សាធ្វើការដាំដុះបានចំនួន ២ ៧១៤ ២១៦ហ.ត ស្មើនឹង១០៤,៨៧% នៃផែនការចំនួន ២ ៥៨៨ ១៣០ហ.ត។ ក្រសួងក៏បានជំរុញដល់គ្រប់អង្គភាពជំនាញទាំងអស់ ជាពិសេសមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត ឱ្យយកចិត្តទុកដាក់គិតគូរទៅលើយន្តការ និងបទដ្ឋានបច្ចេកទេសគន្លឹះសំខាន់ៗ តាមការចាំបាច់ និងសហការចុះអន្តរាគមន៍ទាន់ពេលវេលាក្នុងការតាមដានវាយតម្លៃអំពីការប៉ះពាល់ និងខូចខាតដោយគ្រោះធម្មជាតិ ការរាតត្បាតដោយសត្វល្អិតចង្រៃ ការកើតជំងឺផ្សេងៗលើដំណាំកសិកម្ម ជំងឺឆ្លងសត្វ និងការត្រៀមលក្ខណៈនៅពេលកសិករទទួលរងនូវផលប៉ះពាល់ផ្សេងៗជាយថាហេតុ។

អង្គភាពជំនាញនៅតែខិតខំបន្តពង្រឹងការអនុវត្តច្បាប់ ការកសាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗតាមការចាំបាច់យ៉ាងយកចិត្តទុកដាក់ ដូចជាការជំរុញឱ្យចុះត្រួតពិនិត្យ និងចាត់វិធានការជាក់ស្តែង ដើម្បីលុបបំបាត់បទល្មើសចលនាសត្វឈឺក្នុងតំបន់ផ្ទុះជំងឺ បទល្មើសព្រៃឈើ និងជលផលតាមគ្រប់រូបភាព ព្រមទាំងសហការពង្រឹងយន្តការគ្រប់គ្រង ការត្រួតពិនិត្យអនាម័យ និងភូតគាមអនាម័យដោយគិតគូរជាចម្បងទៅលើគុណភាព សុវត្ថិភាព និងសុខុមាលភាពសាធារណៈ។ ជាមួយគ្នានេះ ក្រសួងក៏បានបន្តជំរុញឱ្យគណៈកម្មការ និងក្រុមការងារដែលបានរៀបចំរួចហើយដើម្បីចូលរួមដោះស្រាយលើរាល់បញ្ហាប្រឈមទាំងឡាយដែលកើតឡើងនៅតាមអនុវិស័យនីមួយៗ។ ទន្ទឹមនឹងនេះ ផ្នែកសេវាកម្ម ដំណើរការនៃកំណែទម្រង់ផ្សេងៗតាមអនុវិស័យសំខាន់ៗ ជាអាទិ៍ក្នុងក្របខ័ណ្ឌកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ ការប្រមូលចំណូលបង់ចូលថវិកាជាតិ កិច្ចការសវនកម្ម ការចុះធ្វើអធិការកិច្ចតាមបណ្តាអង្គភាពក្រោមឱវាទ ការចុះធ្វើអធិការកិច្ចលើការធ្វើអាជីវកម្មសម្ភារកសិកម្ម កិច្ចសហប្រតិបត្តិការអន្តរជាតិ ការរៀបចំវគ្គបណ្តុះបណ្តាល សិក្ខាសាលា រួមទាំងការរៀបចំផែនការយុទ្ធសាស្ត្រ គោលនយោបាយតាមអនុវិស័យសំខាន់ៗឱ្យសម្រេចបាននូវលទ្ធផលល្អប្រសើរតាមផ្នែកនីមួយៗស្របតាមគោលការណ៍ និងទិសដៅដែលត្រូវអនុវត្តក្នុងផែនការអភិវឌ្ឍន៍វិស័យកសិកម្ម។

ជារួម ដោយមានការជួយឧបត្ថម្ភគាំទ្រគ្រប់បែបយ៉ាងពីរាជរដ្ឋាភិបាល ក្រសួង ស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍នានា គួបផ្សំនឹងការខិតខំឧស្សាហ៍ព្យាយាម និងការផ្លាស់ប្តូរទម្លាប់របស់ប្រជាកសិករផង បានជំរុញឱ្យដំណើរការផលិតកម្មកសិកម្មទទួលបានជោគជ័យ និងជម្នះដោះស្រាយនូវរាល់ការលំបាកផ្សេងៗប្រកបដោយមោទនភាព ពិតមែនតែនៅមានបញ្ហាប្រឈមខ្លះៗក៏ដោយ។

## IV- ទិសដៅអនុវត្តបន្ត

### ១ ផ្នែកដាំដុះ

- បន្តវិធានការជំរុញការងារបង្កបង្កើនផលកសិកម្មនៅក្នុងរដូវវស្សាឆ្នាំ២០២០
- បន្តធ្វើការពិនិត្យសន្និធិស្បៀងសម្រាប់ឆ្លើយតបទៅនឹងហានិភ័យនៃការឆ្លងរាលដាលជំងឺកូវីដ-១៩
- បន្តជំរុញដល់អង្គភាពជំនាញក្រោមឱវាទ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តទាំងអស់ចាត់វិធានការតាមគ្រប់រូបភាពដើម្បីជំរុញការងារបង្កបង្កើនផលស្រូវ និងដំណាំកសិកម្មផ្សេងទៀតតាមរយៈការអនុវត្តបច្ចេកទេសកសិកម្មសមស្របឱ្យបានទាំងបរិមាណ និងគុណភាពតាមផែនការកំណត់ ជាពិសេសនៅតំបន់ភូមិសាស្ត្រដែលមានប្រភពទឹកស្រោចស្រពគ្រប់គ្រាន់ និងការរក្សាទឹកទុកទៅតាមស្ថានភាពជាក់ស្តែង
- បន្តជំរុញ និងបណ្តុះបណ្តាលមន្ត្រីបច្ចេកទេស និងកសិករអំពីបច្ចេកទេសដាំដុះដំណាំឧស្សាហកម្ម និងបន្តការសិក្សាស្រាវជ្រាវបច្ចេកទេសដាំដុះដំណាំឧស្សាហកម្ម ការងារផលិតពូជ និងបន្សុទ្ធពូជនៅកសិដ្ឋាន និងស្ថានីយ
- ត្រៀមលក្ខណៈមានដូចជា៖ ស្រូវពូជ ពូជបន្លែ មធ្យោបាយ និងសម្ភារសម្រាប់អន្តរាគមន៍នៅពេលមានគ្រោះមហន្តរាយជាយថាហេតុ ការទប់ទល់នឹងជំងឺ ឬសត្វល្អិតចង្រៃបំផ្លាញដំណាំផ្សេងៗ ព្រមទាំងបន្តរៀបចំពង្រឹងសហគមន៍កសិកម្ម ការធ្វើផលិតកម្មកសិកម្មតាមកិច្ចសន្យាឆ្ពោះទៅរកការធ្វើកសិ-ពាណិជ្ជកម្មសម្រាប់ការងារបង្កបង្កើនផល
- បន្តអង្កេតទូទៅអំពីស្ថានភាពជំងឺគ្រប់ឡត់ពិសោធន៍ក្លូនកៅស៊ូ ត្រួតពិនិត្យជំងឺកៅស៊ូ និងការផ្សព្វផ្សាយបច្ចេកទេសនៅតាមបណ្តាខេត្តដែលមានសក្តានុពលកៅស៊ូ។

### ២ ផ្នែកផលិតកម្មសត្វ និងសុខភាពសត្វ

- បន្តចាត់វិធានការដោយសហការជាមួយក្រសួង ស្ថាប័ន និងអាជ្ញាធរមូលដ្ឋាន ដើម្បីចុះពិនិត្យនិងតាមដានលើសភាពការណ៍ជំងឺឆ្លងសត្វផ្សេងៗទៀត ព្រមទាំងចាត់ក្រុមការងារចុះអប់រំ ណែនាំ និងជំរុញអង្គភាពជំនាញក្រោមឱវាទ រួមទាំងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត ដើម្បីត្រៀម និងចាក់ថ្នាំវ៉ាក់សាំងបង្ការការពារជំងឺសត្វ ការធ្វើអនាម័យសត្វ ការព្យាបាល សង្គ្រោះសត្វ និងវិធានការអន្តរាគមន៍តាមជាក់ស្តែង
- បន្តធ្វើការអប់រំណែនាំដល់ប្រជាកសិករឱ្យបង្កើនការថែទាំបន្ថែមទៀត ព្រមទាំងចាត់ក្រុមអន្តរាគមន៍ឱ្យចុះជាប់ជាប្រចាំ ដើម្បីទប់ស្កាត់បទល្មើសចលនាសត្វដោយខុសច្បាប់នៅតាមបណ្តារាជធានី-ខេត្ត ជាពិសេសខេត្តនៅជាប់ព្រំដែន
- ចុះពិនិត្យអនាម័យសត្តឃាតដ្ឋាន ផ្សព្វផ្សាយអំពីលក្ខណៈនិងសញ្ញាណជំងឺជ្រូកគ្រុនចៀកខៀវ ប៉េស្ត ជំងឺផ្តាសាយបក្សី ជំងឺអាសន្នរោគ និងវិធានការទប់ស្កាត់នៅតាមរាជធានី-ខេត្ត
- បន្តការតាមដានស្ថានភាពជំងឺស៊ូណូសជាប្រចាំនៅតាមបណ្តារាជធានី-ខេត្ត
- ត្រៀមលក្ខណៈចុះអនុវត្តវិធានបសុពេទ្យ កន្លែងផ្ទុះជំងឺ និងកន្លែងដែលរាលដាលជំងឺផ្តាសាយបក្សី (H5N1) និងជំងឺ A(H1N1)
- បន្តអនុវត្តការបង្កាត់ពូជគោ និងជ្រូកដោយសិប្បនិម្មិត។

### ៣ ផ្នែកព្រៃឈើ

- ខិតខំបន្តត្រួតពិនិត្យ តាមដាន និងពង្រឹងការគ្រប់គ្រងសកម្មភាពឧស្សាហកម្មឈើ រោងចក្រ សិប្បកម្មកែច្នៃ និងអាជីវកម្មឈើឲ្យបានហ្មត់ចត់ ព្រមទាំងចាត់វិធានការទប់ស្កាត់ និងលុបបំបាត់ការនាំចេញឈើ និងផលិតផលកែច្នៃឈើគ្រប់ប្រភេទដែលគ្មានការអនុញ្ញាតដើម្បីលុបបំបាត់សកម្មភាពដឹកជញ្ជូនឈើខុសច្បាប់ឲ្យមានប្រសិទ្ធភាពខ្ពស់
- បន្តពង្រឹង និងពង្រីកសហគមន៍ព្រៃឈើឲ្យចូលរួមគ្រប់គ្រងថែរក្សាធនធានព្រៃឈើ តាមដានត្រួតពិនិត្យ ការអនុវត្តផែនការគ្រប់គ្រងព្រៃសហគមន៍ឲ្យបានល្អ ព្រមទាំងបណ្តុះផ្នត់គំនិតបង្កើតមុខរបរថ្មីៗបន្ថែមទៀត ដើម្បីបង្កើនចំណូលតាមរយៈប្រព័ន្ធកសិ-រុក្ខកម្ម ការចិញ្ចឹមសត្វ សំដៅកាត់បន្ថយការពឹងអាស្រ័យលើផល និងអនុផលព្រៃឈើ ជាពិសេសខិតខំជំរុញការផ្សព្វផ្សាយ អប់រំ បណ្តុះបណ្តាល បំពាក់បំប៉នដល់សហគមន៍មូលដ្ឋាន ឲ្យយល់ដឹងពីផលប្រយោជន៍ព្រៃឈើ
- បន្តផ្សព្វផ្សាយច្បាប់ស្តីពីព្រៃឈើ បទប្បញ្ញត្តិ បទបញ្ជា លិខិតបទដ្ឋានគតិយុត្ត ជាពិសេសសេចក្តីជូនដំណឹងលេខ១៣៤៨ សជណ.កជ ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៩ របស់ទីស្តីការគណៈរដ្ឋមន្ត្រីឲ្យបានជ្រួតជ្រាបដល់មូលដ្ឋានភូមិ ឃុំ សង្កាត់ ស្រុក ខណ្ឌ ក្រុង រាជធានី-ខេត្តទូទាំងប្រទេស ព្រមទាំងមានចំណាត់ការផ្លូវច្បាប់យ៉ាងម៉ឺងម៉ាត់ និងឲ្យមានប្រសិទ្ធភាពខ្ពស់ពាក់ព័ន្ធនឹងការកាប់រាន ដុត ឈូសឆាយ និងហ៊ុមព័ទ្ធដីព្រៃឈើដើម្បីវាតយកដីធ្វើកម្មសិទ្ធិ
- បន្តជំរុញការដាំដុះស្តារព្រៃឈើឡើងវិញដោយសហការជាមួយវិស័យឯកជន ដៃគូអភិវឌ្ឍន៍ ព្រមទាំងបង្កើនការបណ្តុះកូនឈើគ្រប់ប្រភេទនៅតាមស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើសម្រាប់ចែកចាយជូនប្រជាពលរដ្ឋ។

**៤ ផ្នែកជលផល**

- ពង្រឹងកិច្ចសហការជាប់ជាប្រចាំជាមួយអាជ្ញាធរដែនដី គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីទប់ស្កាត់និងបង្រ្កាបបទល្មើសជលផល ជាពិសេសការយកចិត្តទុកដាក់អនុវត្តឱ្យបានហ្មត់ចត់នូវសេចក្តីសម្រេច លេខ១២៨ សសរ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៦ របស់រាជរដ្ឋាភិបាលស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួងដើម្បីទប់ស្កាត់ និងបង្រ្កាបបទល្មើសនេសាទនៅបឹងទន្លេសាប

- ជំរុញសង្កាត់ ផ្នែក ខណ្ឌរដ្ឋបាលជលផល និងអធិការដ្ឋានរដ្ឋបាលជលផល បន្តពង្រឹងការអនុវត្តច្បាប់ស្តីពី ជលផលឱ្យបានតឹងរឹងបំផុត

- បន្តពង្រឹងសមត្ថភាពសហគមន៍នេសាទ ដើម្បីលើកកម្ពស់ការទទួលខុសត្រូវ និងភាពជាម្ចាស់លើការគ្រប់គ្រង ធនធានជលផលក្នុងកន្លែងនេសាទរបស់ខ្លួនដោយអនុវត្តយន្តការ "សហគមន៍នេសាទគ្មានបទល្មើសជលផល"។

**៥ ផ្នែកពាក់ព័ន្ធផ្សេងៗ**

- បន្តចុះទប់ស្កាត់បទល្មើសផ្សេងៗពាក់ព័ន្ធការអនុវត្តច្បាប់ ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្មនៅតាម រាជធានី-ខេត្ត។ ជំរុញអនុវត្តកម្មវិធីផ្សព្វផ្សាយ ការយល់ដឹងពាក់ព័ន្ធនឹងការគ្រប់គ្រងការធ្វើអាជីវកម្ម ការកាន់កាប់ ប្រើប្រាស់ ជី-ថ្នាំកសិកម្មឱ្យបានកាន់តែទូលំទូលាយដល់មន្ត្រី អាជីវករ និងអ្នកប្រើប្រាស់ជី-ថ្នាំកសិកម្ម ដើម្បីសុខភាពសាធារណៈ

- បន្តពង្រឹងការងារបញ្ជិកាគណនេយ្យ ការគ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យនៅតាមបណ្តាអង្គភាពក្រោមឱវាទនិង បណ្តាមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តក៏ដូចជាការតម្រង់ទិសទៅរកការអនុវត្តថវិកាតាមកម្មវិធីពេញលេញ ក្នុងក្របខ័ណ្ឌកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈឱ្យមានប្រសិទ្ធភាព និងទទួលបានលទ្ធផលល្អប្រសើរតាមការរំពឹងទុក

- បន្តចុះពិនិត្យផ្ទាល់ដល់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ដើម្បីមានមូលដ្ឋានរាយការណ៍ឱ្យបានច្បាស់លាស់សម្រាប់ ផ្ទៀងផ្ទាត់ទៅនឹងការអនុវត្តផែនការមេ និងយកចិត្តទុកដាក់លើការប្រមូលចំណូលសម្រាប់បង់ចូលថវិកាជាតិឱ្យបានសម ស្របតាមនីតិវិធី

- បន្តចុះធ្វើអធិការកិច្ចនិងកិច្ចការសវនកម្មតាមបណ្តាអង្គភាពក្រោមឱវាទ និងតាមសកម្មភាពជាក់ស្តែង រួមទាំង ការរៀបចំវគ្គបណ្តុះបណ្តាលតាមផែនការប្រចាំឆ្នាំដែលបានគ្រោងទុក

- បន្តកិច្ចសហប្រតិបត្តិការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ អង្គភាពជំនាញ រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ វិស័យឯកជន សង្គមស៊ីវិល និងសហគមន៍កសិកម្ម ដើម្បីរិះរកដំណោះស្រាយលើរាល់បញ្ហាប្រឈមនៅតាមអនុវិស័យ នីមួយៗលើគ្រប់មធ្យោបាយក្នុងស្មារតីស្ថាបនា អភិវឌ្ឍន៍វិស័យកសិកម្មនៅកម្ពុជាឱ្យមានផលិតភាពខ្ពស់ដោយគិតគូរ ទៅលើការប្រែប្រួលអាកាសធាតុ និងស្តង់ដារ៕

ថ្ងៃសុក្រ ១២កើត ខែអស្សុជ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែតុលា ឆ្នាំ២០២០

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**